# ស្ថានីយបុរាណដែកនៃឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានមនុស្សរស់នៅតាំងពីយុគថ្មរំលីង ២000ឆ្នាំមុនគ្រិស្តសករាជ?

ដោយៈ ផ្នែកបុរាណវត្ថុវិទ្យានៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ
(បណ្ឌិត ផុន កសិកា លោក ហឿង សុធារស់ លោក ជ័យ រតនា និងកញ្ញា តាកេត ស័កដា)

ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប បង្កើតឡើងដោយព្រះរាជក្រឹតលេខ៖ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ មានផ្ទៃដីក្រឡាចំនួន១១៤៣៥ហិចតា[1] ដែលមានទីតាំងស្ថិតក្នុងឃុំឆែប១ និងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ ស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា ដែលជាតំបន់ខ្ពស់ និងនៅជិតតំបន់ភ្នំ ក្នុងកម្រិតកម្ពស់១២០ម៉ែត្រពីទឹកសមុទ្រ។



ផែនទីបង្ហាញពីទីតាំងស្រុកឆែបស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា (ប្រភព៖ Google Earth)

[1] ព្រះរាជក្រឹតស្តីពី *ការបង្កើត "ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប"* លេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤




ផែនទីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និងទីតាំងស្ថានីយបុរាណដែលបានរកឃើញនៅឆ្នាំ២០១៧

នៅឆ្នាំ២០១៧ វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាស្ថាប័នចំណុះនៃរាជបណ្ឌិត្យសភាកម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវស្តីពី «មរតកវប្បធម៌រូបី និងអរូបី នៅតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប» ដោយមានការចូលរួមពីមន្ត្រីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប បានរុករកនិងរកឃើញស្ថានីយបុរាណដែលជាមរតកវប្បធម៌រូបីចំនួន១២៤ មានដូចជា៖ ទួលសន្លុង (ទួលឡស្លដែក) ចំនួន៤៣, ត្រពាំងសន្លុង[2] (ត្រពាំងតូចៗដែលគេជីកនៅជាប់ទួលសន្លុង) ចំនួន១៧, ត្រពាំង[3]ចំនួន៦៤ និងបុរាណវត្ថុ

[2] ជាស្នាមជីកតូចឬធំ រាងដូចត្រពាំង មានទំហំតូចឬធំ និងជម្រៅមិនជ្រៅដូចត្រពាំងទេ។ នៅរដូវភ្លៀងធ្លាក់ តែងមានទឹកដក់ ហើយទឹកនេះនឹងរីងវិញនៅខែមីនា និងមេសា។ ត្រពាំងសន្លុងច្រើនជីកនៅជាប់ជើងទួលសន្លុង។ ដោយសារលក្ខណៈរូបរាងដូចត្រពាំង ហើយជីកនៅជាប់ទួលសន្លុង ក្រុមស្រាវជ្រាវក៏ហៅឈ្មោះថា "ត្រពាំងសន្លុង"។

[3] ត្រពាំងមានពីរប្រភេទ៖ ត្រពាំងជីក និងត្រពាំងធម្មជាតិ។ ទោះបីជាត្រពាំងធម្មជាតិ ត្រពាំងទាំងនោះមានទំនាក់ទំនងនឹងមនុស្សដែលតែងតែមកប្រើប្រាស់ទឹកត្រពាំងជាប្រចាំ។ ភស្តុតាងនៃការប្រើប្រាស់ត្រពាំងក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ដោយសារមានផ្លូវក្នុងព្រៃតែងភ្ជាប់ទៅនឹងត្រពាំង។

មួយចំនួនដូចជា៖ កុលាលភាជន៍ ត្រឡែកតូច ត្រឡែកធំ និងឧបករណ៍ផលិតពីដែក មានផ្លែចបជីកចំនួន១ ផ្លែជីងចំនួន១០ ចង្កឹដងកាំបិតចំនួន៤ ដងកាំបិតចំនួន១ និងដែកគោលចំនួន២[4]។

នៅឆ្នាំ២០១៨ មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈបន្តសិក្សាស្រាវជ្រាវនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប បានរកឃើញស្ថានីយបុរាណ និងវត្ថុបុរាណបន្ថែមមួយចំនួនទៀតមានទួលសន្លុង (ទួលឡស្លដែក) ចំនួន៥៤ ដែលស្ថិតនៅក្នុងបណ្តុំទួលសន្លុងចំនួន៥ផ្សេងគ្នា៖ ១-បណ្តុំទួលសន្លុងត្រពាំងត្រើបមានទួលសន្លុងចំនួន១៥, ២-បណ្តុំទួលសន្លុងត្រពាំងឫស្សីត្រើបមានទួលសន្លុងចំនួន១៧, ៣-បណ្តុំទួលសន្លុងភូមិកំបុតចាស់ មានទួលសន្លុងចំនួន១០, ៤-បណ្តុំទួលសន្លុងត្រពាំងឫស្សីបល្ល័ង្ក មានទួលសន្លុងចំនួន៦ និង ៥-បណ្តុំទួលសន្លុងត្រពាំងក្រសាំង មានទួលសន្លុងចំនួន៦។ ក្រៅពីនេះ ការស្រាវជ្រាវក៏បានរកឃើញត្រពាំងសន្លុងចំនួន២៩ ត្រពាំងបុរាណចំនួន៦៦ និងបុរាណវត្ថុមួយចំនួន ដូចជា កុលាលភាជន៍ ត្រឡែកតូច ត្រឡែកធំ ដុំថ្មភក់ប្រើក្នុងការស្មិតដែក ផ្លែចបជីក ផ្លែជីង ចង្កឹដងកាំបិត ដងកាំបិត និង ដែកគោលជាដើម។

ក្រៅពីទួលសន្លុង ត្រពាំងសន្លុង ត្រពាំង និងវត្ថុបុរាណដូចបានរៀបរាប់ខាងលើ ក្រុមការងារស្រាវជ្រាវបានរកឃើញឧបករណ៍ថ្មសម័យបុរេប្រវត្តិសាស្ត្រមួយ ស្ថិតនៅជិតការិយាល័យនៃឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប និងនៅជិតបណ្តុំទួលឡស្លដែកត្រពាំងឫស្សីត្រើប មានចំណុចនិយាមការ (X: 48 P 0553112, Y: 1535315)។ ឧបករណ៍ថ្មនេះជាប្រភេទឧបករណ៍ថ្មរំលីងមានរាងដូចផ្លែពូថៅ រួមខាងក្បាល រីកនៅផ្នែកខាងផ្លែ មានមុខស្តើង ដែលអាចប្រើប្រាស់សម្រាប់កាត់ ពុះ រួមទាំងកាប់ផងដែរ។ ឧបករណ៍ថ្មនេះ មានបណ្តោយ៥,៥ សង់ទីម៉ែត្រនិងទទឹង៤សង់ទីម៉ែត្រ(ផ្នែកខាងផ្លែ) និងកម្រាស់១សង់ទីម៉ែត្រ។




ឧបករណ៍ថ្មរំលីងទើបរកឃើញនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប (រូបខាងឆ្វេងថតខាងផ្ងារ និងរូបខាងស្តាំថតខាងផ្កាប់)

[4] នូ ចាន់សុភី, ផុន កសិកា, ប្រែង ពិសិដ្ឋ... "*មរតកវប្បធម៌រូបី និងអរូបីនៅតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប*", វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ, រាជបណ្ឌិត្យសភាកម្ពុជា, ២០១៧។



ឧបករណ៍ថ្មរំលីងទើបរកឃើញនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប (រូបចំហៀង)

ឧបករណ៍ថ្មរំលីង គឺជាវត្ថុមួយ ដែលមនុស្សក្នុងសម័យបុរេប្រវត្តិផលិតនិងយកមកប្រើសម្រាប់ធ្វើកសិកម្ម ដាំដំណាំ កាប់ព្រៃឈើជាដើម។ ក្នុងសម័យនោះ គេចាត់ទុកថាជាសម័យកំណើតកសិកម្មដំបូងបង្អស់ បន្ទាប់ពីមនុស្សរស់នៅក្នុងសម័យថ្មបំបែកដែលប្រកបមុខរបរចិញ្ចឹមជីវិតដោយប្រមាញ់និងរុករកផលព្រៃឈើ ព្រមទាំងតាំងទីលំនៅក្នុងរូងភ្នំ។ ចំណែកមនុស្សសម័យថ្មរំលីង ចាប់ផ្តើមចេញពីរូងភ្នំ មករស់នៅតាមតំបន់ទំនាប ដើម្បីធ្វើកសិកម្ម ផ្សាំពូជដំណាំផ្សេងៗ និងផ្សាំងសត្វ ដូចជាសត្វឆ្កែ ពពែ ចៀម ជ្រូក គោ ក្របីយកមកចិញ្ចឹមជាដើម និងបរបាញ់សត្វ នេសាទ រុករកអនុផលព្រៃឈើ ព្រមទាំងរស់នៅប្រមូលផ្តុំគ្នាជាសហគមន៍ធំៗ។ មនុស្សក្នុងសម័យថ្មរំលីងចេះសង់ទីលំនៅដ្ឋានជាក់លាក់នៅតាមទីវាលក្បែរប្រភពទឹក។

បើតាមការកំណត់កាលបរិច្ឆេទរបស់លោក *ឆាល ហាយហេម* (Charles F. W. Higham) ឧបករណ៍ថ្មរំលីងដែលស្ថិតក្នុងយុគថ្មរំលីង ឬសម័យថ្មរំលីង មានអាយុកាលប្រហែលចាប់ពីរវាងឆ្នាំ៨០០០-៦០០០មុនគ្រិស្តសករាជ ប៉ុន្តែនៅតំបន់អាស៊ីអាគ្នេយ៍វិញ ការកំណត់អាយុកាលយុគថ្មរំលីង ចាប់ពី២៥០០-២០០០ឆ្នាំមុនគ្រិស្តសករាជ[5]។ លោក Charles F. W. Higham ក៏បានសន្និដ្ឋានដែរថា ការធ្វើកសិកម្មស្រូវដំបូងៗ បានកើតឡើងនៅតំបន់ជ្រលងទន្លេយ៉ាងហ្ស៊ី (Yangzi) និងជ្រលងទន្លេលឿង (Yellow River) ហើយបានបន្តមកតំបន់អាស៊ីអាគ្នេយ៍នៅ៣០០០ឆ្នាំមុនគ្រិស្តសករាជ ដែលស្ថិតក្នុងយុគថ្មរំលីង[6]។ រីឯនៅប្រទេសកម្ពុជាវិញ យុគថ្មរំលីងមានអាយុប្រហែល២០០០ឆ្នាំមុនគ្រិស្តសករាជ[7]។

---

[5] ឆាល ហាយហេម, *វប្បធម៌ដំបូងនៃតំបន់អាស៊ីអាគ្នេយ៍ដីគោក* បកប្រែជាភាសាអង់គ្លេសពីសៀវភៅឈ្មោះ "Early Culture of Mainland Southeast Asia", អង្គការបុរាណវិទ្យាខ្មែរ និងរាជបណ្ឌិត្យសភាកម្ពុជា, ទំព័រ ២៧, ២០១៣។

[6] Higham, Charles., First Farmers in Mainland Southeast Asia, in JOURNAL OF INDO-PACIFIC ARCHAEOLOGY 41 (2017): 13-21

[7] ហេង សុផាឌី និង ហេង ថាន, *បុរេប្រវត្តិសាស្ត្រ ៖ ប្រវត្តិនៃការសិក្សាស្រាវនិងបញ្ជីស្ថានីយ* ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ទំព័រ៨២, ២០១៤។

បើយើងមើលពីទីតាំងផ្សេងៗនៅក្បែរឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹបវិញ ដូចជានៅភូមិសង្កែ ដែលស្ថិតនៅក្បែរតំបន់នោះ ត្រូវបានអ្នកស្រាវជ្រាវជនជាតិបារាំង មានលោក **អេតម៉ុង សូរាំង** នៅឆ្នាំ១៩៦៣ បានរកឃើញភស្តុតាងទីតាំងរស់នៅដំបូងៗ ដែលជាស្ថានីយស្ថិតក្នុងយុគ**គ្រួសបំបែក**[8] ដោយលោកបានដាក់ឈ្មោះថា "**ស្ថានីយឆែប**" ហើយសព្វថ្ងៃស្ថិតនៅក្នុងភូមិសង្កែ ឃុំឆែប១ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានចម្ងាយប្រមាណជាង១០គីឡូម៉ែត្រ ពីស្ថានីយឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប។

ទីតាំងមួយទៀតដែលស្ថិតនៅមិនឆ្ងាយពីស្ថានីយឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹបដែរនោះ គឺ "**ស្ថានីយម្លូព្រៃ**" ដែលសព្វថ្ងៃស្ថិតនៅក្នុងភូមិម្លូព្រៃ ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ ក៏បន្សល់ភស្តុតាងនៃការតាំងទីលំនៅរបស់មនុស្សក្នុងសម័យបុរេប្រវត្តិសាស្ត្រ ក្នុងយុគ**ថ្មរំលីង** ហើយការសិក្សាស្រាវជ្រាវនិងធ្វើកំណាយនេះបានធ្វើឡើងដោយលោក **ប៉ូល ទ្បេវី** ក្នុងឆ្នាំ១៩៤៣[9]។ ក្រៅពីស្ថានីយទាំងឡាយក្នុងស្រុកឆែប ខេត្តព្រះវិហារ មានស្ថានីយបុរេប្រវត្តិសាស្ត្រក្នុងប្រទេសកម្ពុជាដែលគេកំណត់កាលបរិច្ឆេទក្នុងយុគថ្មរំលីង ដូចជាស្ថានីយល្អាងស្ពាន[10], ស្ថានីយសំរោងសែន[11], ស្ថានីយក្រែក[12] ជាដើម។

---

[8] ហេង សុផាឌី និង ហេង ថាន *បុរេប្រវត្តិសាស្ត្រកម្ពុជា៖ ប្រវត្តិនៃការសិក្សាស្រាវជ្រាវ និងបញ្ជីស្ថានីយ* ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ២០១៤។

[9] ហេង សុផាឌី និង ហេង ថាន *បុរេប្រវត្តិសាស្ត្រកម្ពុជា៖ ប្រវត្តិនៃការសិក្សាស្រាវជ្រាវ និងបញ្ជីស្ថានីយ* ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ២០១៤។

[10] Mourer, Roland., Laang Spean and the Prehistory of Cambodia, in Modern Quaternary Research in Southeast Asia, January 1977.

[11] Ly Vanna, Rice Remains in the Early Prehistoric Pottery Tempers of the Shell Midden Site of Samrong Sen: Implications for Early Rice Cultivation in Central Cambodia. In Aséanie, 2002, pp. 13-34.

[12] Albrecht, Gerd., Circular Earthwork Krek 52/62: Recent Research on the Prehistory of Cambodia, in Asian Perspective, Vol. 39, No 1-2, 2001.



*រូបគំនូនៃសមុច្ច័យដែលប្រមូលពីស្ថានីយម្លូព្រៃបន្ទាប់ពីលោក ប៉ូល ឡេវី ធ្វើកំណាយនៅឆ្នាំ១៩៣៨*
*រូបខាងស្តាំ ជួរទី២គឺជាប្រភេទថ្មរំលីង* (ប្រភព៖ ហេង សុផាឌី និង ហេង ថាន *បុរេប្រវត្តិសាស្ត្រកម្ពុជា៖ ប្រវត្តិនៃការសិក្សាស្រាវជ្រាវ និងបញ្ជីស្ថានីយ* ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ២០១៤ ទំព័រ ៩២)

តាមការបង្ហាញខាងលើ តំបន់ក្បែរៗស្ថានីយឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានការតាំងទីលំនៅរបស់មនុស្សតាំងពីរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជមកហើយ ជាពិសេស **ស្ថានីយម្លូព្រៃ** ត្រូវបានលោក **ប៉ូល ឡេវី** សន្និដ្ឋានថាមានអាយុកាលក្នុងយុគ**ថ្មរំលីង**។ ទោះបីរបកគំហើញថ្មីនេះ រកឃើញថ្មរំលីងតែមួយដុំក៏ពិតមែន តែភស្តុតាងថ្មមួយដុំនេះជាចំណែកបង្ហាញថា ស្ថានីយឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានមនុស្សមករស់នៅប្រហែលតាំងពីយុគថ្មរំលីង នៅ២០០០ឆ្នាំមុនគ្រិស្តសករាជ បន្ទាប់ពីមនុស្សសម័យថ្មបំបែកចេញពីរូងភ្នំមករកទីជម្រកតាមទីវាលក្បែរប្រភពទឹក ដើម្បីធ្វើកសិកម្មនិងចិញ្ចឹមសត្វ។ បើយើងពិនិត្យមើលពីទេសភាព និងទិដ្ឋភាពភូមិសាស្ត្រ នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានអូរមួយឈ្មោះ "អូរតាឡាស់" ផ្តល់ទឹកជាប្រចាំអាចផ្គត់ផ្គង់ដល់ការរស់នៅប្រចាំថ្ងៃរបស់មនុស្សបាន។ អូរក៏ជាប្រព័ន្ធគមនាគមន៍មួយអាចឲ្យមនុស្សធ្វើទំនាក់ទំនងគ្នាពីតំបន់មួយទៅតំបន់មួយទៀតបាន[13]។ ស្ថានភាព

[13] ឆាល ហាយហេម, *វប្បធម៌ដំបូងនៃតំបន់អាស៊ីអាគ្នេយ៍ដីគោក* បកប្រែជាភាសាអង់គ្លេសពីសៀវភៅឈ្មោះ "Early Culture of Mainland Southeast Asia", អង្គការបុរាណវិទ្យាខ្មែរ និងរាជបណ្ឌិត្យសភាកម្ពុជា, ទំព័រ ២៧, ២០១៣។

ភូមិសាស្ត្រជាដីមានព្រៃផង និងមានវាលទំនាបផងដែលអំណោយផលដល់ការធ្វើកសិកម្ម និងចិញ្ចឹមសត្វបានដែរនោះ ទើបបានជាមនុស្សនៅយុគថ្មរំលីងអាចជ្រើសរើសទីតាំងនេះសម្រាប់តាំងទីលំនៅ។ ទោះបីមនុស្សនៅក្នុងយុគថ្មរំលីងចាប់ផ្តើមកសាងទីតាំងរស់នៅជាក់លាក់ មនុស្សសម័យនោះនៅតែបន្តរកអាហារចិញ្ចឹមជីវិតដោយបរបាញ់និងរុករកអនុផលព្រៃឈើ និងស្វែងរកផលទាំងនោះនៅតាមទីផ្សេងៗទៀតដែលអាចធ្វើដំណើរទៅបាន។

បើយោងតាមលទ្ធផលស្រាវជ្រាវកន្លងមក ភស្តុតាងនៃការរស់នៅរបស់មនុស្សនៅស្ថានីយឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប អាចកំណត់បានតែក្នុងយុគថ្មរំលីងប៉ុណ្ណោះ ដោយមិនឃើញមានភស្តុតាងបុរាណវត្ថុវិទ្យាបង្ហាញថាមនុស្សយុគក្រោយៗមកទៀត ដូចជាយុគសំរឹទ្ធ យុគដែក មកតាំងទីលំនៅក្នុងឧទ្យាននេះឡើយ។ ភស្តុតាងនៃការរស់នៅរបស់មនុស្សបាត់ដានដ៏វែងឆ្ងាយរហូតដល់ពេលមួយដែលតំបន់នេះ (បច្ចុប្បន្នតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប) ចាប់ផ្តើមមានការមកតាំងទីលំនៅឡើងវិញ ហើយប្រែក្លាយជាតំបន់ផលិតដែកធំមួយក្នុងសម័យអង្គរ (ចាប់ពីសតវត្សទី១១ ដល់សតវត្សទី១៣) ក្នុងចំណោមតំបន់ផលិតដែកផ្សេងៗទៀតដូចជានៅតំបន់ភ្នំដែក ស្រុករវៀង និងតំបន់ប្រាសាទព្រះខ័នកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តព្រះវិហារ។

ការសិក្សាស្រាវជ្រាវឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនៅស្ថានីយឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប រួមទាំងការធ្វើកំណាយ និងការវិភាគតាមបែបវិទ្យាសាស្ត្រមួយចំនួនទៀត ត្រូវតែអនុវត្តនៅថ្ងៃអនាគត ដើម្បីបញ្ជាក់ពីការតាំងទីលំនៅដ៏ជាក់លាក់របស់មនុស្សក្នុងយុគថ្មរំលីង អាយុកាលរបស់ស្ថានីយតាមរយៈការវិភាគវិទ្យុសកម្មធ្យូង និងចំណោទបញ្ហាស្រាវជ្រាវមួយចំនួនទៀត។

ទន្ទឹមនោះ ការសិក្សាដើម្បីកំណត់ទីតាំងជាក់លាក់របស់ស្ថានីយឆែបនិងស្ថានីយម្លូព្រៃក៏ជារឿងដ៏មានសារៈសំខាន់ដែរ ទោះបីកន្លងមកមានអ្នកស្រាវជ្រាវខ្មែរនិងបរទេសបានធ្វើកិច្ចការនេះហើយក្តី។ ជាក់ស្តែង តាមការសិក្សារបស់លោក ហេង សុផាឌី និងលោក ហេង ថាន បង្ហាញថា ស្ថានីយ*ឆែប* (និយាមការៈ ៥២៧៥៣៦ និង ១៥៤៥១៨៦) ដែលមានទីតាំងស្ថិតក្នុងភូមិសង្កែ ឃុំឆែប១ ស្រុកឆែប ខេត្តព្រះវិហារ។ បើយោងតាមឈ្មោះស្ថានីយឆែប ស្ថិតក្នុងភូមិសង្កែ ឃុំឆែប១ ស្ថានីយនេះគួរតែស្ថិតនៅទីតាំងណាមួយក្នុងភូមិសង្កែដែលស្ថិតនៅភាគខាងត្បូង។ ប៉ុន្តែនៅពេលដែលយើងយកចំណុចនិយាមការខាងលើបញ្ចូលក្នុងផែនទី ស្ថានីយឆែបបែរជាស្ថិតនៅខាងជើងស្រុកឆែបវិញ គឺស្ថិតក្នុងឃុំម្លូព្រៃ មិនមែនស្ថិតក្នុងឃុំឆែប១ ដូចដែលសរសេរក្នុងអត្ថបទនោះឡើយ។ បញ្ហានេះអាចកើតឡើងដោយសារកត់ត្រាតួលេខពីម៉ាស៊ីន GPS មិនបានត្រឹមត្រូវ ឬក៏អាចបណ្តាលមកពីកត់ត្រាឈ្មោះភូមិ និងឈ្មោះឃុំមិនបានត្រឹមត្រូវ។ នេះជាបច្ច័យមួយដែលអ្នកស្រាវជ្រាវក្រោយៗត្រូវធ្វើការសិក្សា និងស្វែងរកស្ថានីយ ព្រមទាំងកំណត់ទីតាំងឲ្យបានពិតប្រាកដ។




ផែនទីស្ថានីយបុរេប្រវត្តិសាស្ត្រនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និងនៅតំបន់ជិតខាង

(រៀបចំផែនទីដោយៈ ឡេង សត្យា)

## ឯកសារយោង

ព្រះរាជក្រឹតស្តីពី *ការបង្កើត "ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប"* លេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤។

ឆាល ហាយហេម, *វប្បធម៌ដំបូងនៃតំបន់អាស៊ីអាគ្នេយ៍ដីគោក* បកប្រែជាភាសាអង់គ្លេសពីសៀវភៅឈ្មោះ "Early Culture of Mainland Southeast Asia", អង្គការបុរាណវិទ្យាខ្មែរ និងរាជបណ្ឌិត្យសភាកម្ពុជា, ទំព័រ ២៧, ២០១៣។

នូ ចាន់សុភី, ផុន កសិកា, ប្រែង ពិសិដ្ឋ, ម៉ិល វាសនា, ជ័យ រតនា, ហឿង សុធារស់, សរ សិលា, យ៉ាន់ វិភារតន៍, ឈឹម សុខាន់ដារា, សួន សុភា, ស្រី សីហា, សាល់ ខាន់ *"មរតកវប្បធម៌រូបី និងអរូបីនៅតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប"*, វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ, រាជបណ្ឌិត្យសភាកម្ពុជា, ២០១៧។

ហេង សុផាឌី និង ហេង ថាន, *បុរេប្រវត្តិសាស្ត្រ ៖ ប្រវត្តិនៃការសិក្សាស្រាវនិងបញ្ជីស្ថានីយ* ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ទំព័រ៨២, ២០១៤។

Charles F. W. Higham, First Farmers in Mainland Southeast Asia, in JOURNAL OF INDO-PACIFIC ARCHAEOLOGY 41 (2017): 13-21.

Gerd Albrecht, *Circular Earthwork Krek 52/62: Recent Research on the Prehistory of Cambodia*, in Asian Perspective, Vol. 39, No 1-2, 2001.

Ly Vanna, *Rice Remains in the Early Prehistoric Pottery Tempers of the Shell Midden Site of Samrong Sen: Implications for Early Rice Cultivation in Central Cambodia*. In Aséanie, 2002, pp. 13-34.

Roland Mourer, *Laang Spean and the Prehistory of Cambodia*, in Modern Quaternary Research in Southeast Asia, January 1977.